# សេចក្តីជូនដំណឹង

## ស្តីពី

## របាយការណ៍លទ្ធផល ស្តីពីក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) ខូអិលធីឌី បានទទួលការកាន់កាប់បន្ត ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត គីអិលស៊ី

ក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) ខូអិលធីឌី សូមប្រកាសថា ៖ យោងតាមកិច្ចសន្យាទិញលក់រវាងលោកជំទាវឧកញ៉ា លឹម ឈីវហួ និងអ្នកឧកញ៉ា គិត ម៉េង ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ភាគហ៊ុនចំនួន ៣២.៨១០.០០០ ឬ ៤៥,០៩% របស់លោកជំទាវឧកញ៉ា លឹម ឈីវហួ ត្រូវបានលក់ទៅឱ្យក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) ខូអិលធីឌី ដែលកាន់កាប់ដោយអ្នកឧកញ៉ា គិត ម៉េង ក្នុងតម្លៃ ២.១១០ រៀល (ពីរពាន់មួយរយដប់) ក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុប ៦៨.៣៨៥.១០០.០០០ រៀល ឬ ១៦.៧៦៥.១៦៣,០៣ ដុល្លារអាមេរិក តាមរយៈយន្តការជួញដូរដែលត្រូវបានអនុញ្ញាតដោយផ្សារមូលបត្រកម្ពុជា (CSX) នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២១។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធ NTM ដែលភាគីទាំងពីរ (អ្នកលក់ និងអ្នកទិញ) បានទូទាត់សាច់ប្រាក់រួចហើយនៅខាងក្រៅ ផ្សារមូលបត្រកម្ពុជា។

ជាការពិតណាស់ ភាគីទាំងពីរបានប្រតិបត្តិការលើការ លក់ និងទិញដោយឆន្ទៈនិងមានការសម្រេចចិត្តផ្ទាល់ខ្លួនរបស់ភាគីទាំងសងខាង។ លើសពីនេះទៀត កិច្ចព្រមព្រៀងលក់-ទិញភាគហ៊ុនក៏ត្រូវបានទទួលស្គាល់ និងអនុម័តដោយក្រុមប្រឹក្សាភិបាលនៃ ភីភីអេសភី ផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបដោយក្តីអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)
INTER LOGISTICS (CAMBODIA)
Co., Ltd.